ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការណែនាំ

# ស្តីពី

# ការចាត់តាំងអនុវត្តគោលនយោបាយ

# "ភូមិ ឃុំមានសុវត្ថិភាព"

ពង្រឹងនគរបាលមូលដ្ឋានដើម្បីសុវត្ថិភាព ភូមិ-ឃុំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ : ០២០ ផក

# ផែនការណែនាំ
# ស្តីពី
# ការចាត់តាំងអនុវត្តគោលនយោបាយ "ភូមិ,ឃុំមានសុវត្ថិភាព"

សន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ជាកត្តាគន្លឹះដែលផ្តល់ភាពអនុគ្រោះដល់ដំណើរការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងវិស័យផ្សេងទៀតមានការរីកចំរើន ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ របស់រាជរដ្ឋាភិបាលកម្ពុជា ។ ទោះបីយើងមានសន្តិភាព ស្ថេរភាព យ៉ាងរឹងមាំ ប៉ុន្តែសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ជាបញ្ហាដែលត្រូវយកចិត្តទុកដាក់ជាប្រចាំដើម្បីធានាឱ្យប្រជាពលរដ្ឋគ្រប់រូប និងសង្គមទាំងមូលមានសុវត្ថិភាពយ៉ាងល្អប្រសើរ ។

នាឱកាសមិទ្ទិញរំលឹកខួបអនុស្សាវរីយ៍លើកទី ៦៥ ថ្ងៃបង្កើតកងកម្លាំងនគរបាលជាតិកម្ពុជា នាថ្ងៃទី១៧ ខែ ឧសភា ឆ្នាំ២០១០ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាបាន ផ្តល់អនុសាសន៍ជាច្រើន ដែលក្នុងនោះបានកំណត់យកគោល ការណ៍កសាង ភូមិ, ឃុំ មានសុវត្ថិភាព ដើម្បីលើកកំពស់ និងជំរុញចលនាការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនៅ គ្រប់ពេល និងគ្រប់ច្រកល្ហកទូទាំងព្រះរាជាណាចក្រកម្ពុជា។

ផ្អែកតាមអនុសាសន៍ដ៏ថ្លៃថ្លានេះ ក្រសួងមហាផ្ទៃ បានកំណត់យកភូមិ,ឃុំមានសុវត្ថិភាពធ្វើជាគោលនយោបាយ អាទិភាពមួយសម្រាប់កម្លាំងអនុវត្តច្បាប់ អាជ្ញាធរមាន សមត្ថកិច្ចគ្រប់ថ្នាក់ សមាសភាពផ្សេងៗទាំងក្នុងជួររដ្ឋាភិ បាល គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល ផ្នែក ឯកជន និងប្រជាពលរដ្ឋទាំងមូល រួមគ្នាពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈឱ្យបានគត់មត់ល្អនៅគ្រប់ភូមិ, ឃុំ ទូទាំងប្រទេស ។

ដើម្បីអនុវត្តឱ្យបានជោគជ័យគោលនយោបាយខាងលើក្រសួងមហាផ្ទៃសូមធ្វើការណែនាំចាត់តាំងអនុវត្តដែលមានខ្លឹមសារសំខាន់ៗមួយចំនួនដូចខាងក្រោម :

**I-គោលបំណង និងសំណូមពរ :**

១-បន្តកសាង និងពង្រឹងសេចក្តីសុខសុវត្ថិភាពជូនប្រជាពលរដ្ឋនៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលាតាមរយៈការតស៊ូលុបបំបាត់បទល្មើសគ្រប់ប្រភេទក្នុងមូលដ្ឋាន ភូមិ, ឃុំ, សង្កាត់ ទូទាំងព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្កភាពអនុគ្រោះដល់ដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចនៅមូលដ្ឋាន និងឈានទៅបង្កើនល្បឿនកាត់បន្ថយភាពក្រីក្រឱ្យកាន់តែបានល្អប្រសើរថែមទៀត ។

២-បំផុសឱ្យមានកិច្ចសហការចូលរួមជាមួយសមត្ថកិច្ចពីគ្រប់សមាសភាពផ្សេងៗ ទាំងក្នុងជួររដ្ឋាភិបាល គណៈបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល ផ្នែកឯកជន និងប្រជាពលរដ្ឋគ្រប់រូបដើម្បីកសាងបានជាកម្លាំងសរុប វិធានការសរុប និងមធ្យោបាយសរុប ក្នុងការអនុវត្តគោលនយោ

បាយភូមិ,ឃុំមានសុវត្ថិភាព ។

## II-លក្ខណៈសម្បត្តិ ភូមិ,ឃុំ មានសុវត្ថិភាព

ភូមិ, ឃុំ មានសុវត្ថិភាព គឺ ភូមិ,ឃុំ ដែលមាន លក្ខណៈសម្បត្តិ ៥យ៉ាងដូចខាងក្រោម :

១-គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ

២-គ្មានការផលិត ការចែកចាយ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់

៣-គ្មានអំពើអនាចារ្យ ការជួញដូរស្ត្រី និងកុមារ និងអំពើហិង្សាក្នុងគ្រួសារ

៤-គ្មានក្មេងទំនើង

៥-គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ ។

## III-វិធានការ និងផែនការសកម្មភាព

### ក-វិធានការ :

១-ចាត់វិធានការលុបបំបាត់ឱ្យបានបទល្មើស លួច

ឆក់ ប្លន់គ្រប់ប្រភេទ ដែលតែងតែកើតមានឡើងនៅតាមភូមិ ឃុំ សង្កាត់ តាមវិធានការច្បាប់ វិធានការរដ្ឋបាល និងវិធានការមហាជន ។

២-ចាត់វិធានការកាត់ផ្តាច់ និងលុបបំបាត់ឱ្យបានការផលិតការចែកចាយ ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់នៅតាមភូមិ, ឃុំ, សង្កាត់ ដោយអនុវត្តតាមផែនការណែនាំលេខ ០៥២ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៦ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ស្តីពីការអនុវត្តប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន និងជាពិសេសតាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣-ចាត់វិធានការលុបបំបាត់រាល់អំពើអនាចារ្យ ការជួញដូរស្ត្រី និងកុមារ អំពើហិង្សាក្នុងគ្រួសារ ដើម្បីការពារសន្តិសុខ សុវត្ថិភាពជូនប្រជាពលរដ្ឋ ជាពិសេសស្ត្រី និងកុមារឱ្យរួចផុតពីការជួញដូរ អំពើរត់ពន្ធ ការធ្វើអាជីវកម្មលើកម្លាំងពលកម្ម ការធ្វើអាជីវកម្មផ្លូវភេទ និងអំពើហិង្សា ( ឯកសារយោង ផែនការសកម្មភាពលេខ ០២៣ផ.ក ចុះថ្ងៃទី ២៣

ខែកុម្ភៈ ឆ្នាំ២០០៥ របស់ក្រសួងមហាផ្ទៃ ស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរ ការរត់ពន្ធមនុស្ស ការធ្វើអាជីវកម្មលើមនុស្ស និងការធ្វើ អាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ) ដោយអនុវត្តតាមច្បាប់ដែលមានជាធរមានឱ្យបានម៉ឺងម៉ាត់ ។

៤-ចាត់វិធានការទប់ស្កាត់ និងបង្ក្រាបសកម្មភាពក្មេងទំនើងឱ្យបានទាន់ពេល និងមានប្រសិទ្ធភាពដើម្បីធានារក្សាបរិយាកាសសន្តិសុខ សុវត្ថិភាព ភូមិ, ឃុំ, សង្កាត់ល្អប្រសើរ (ឯកសារយោង សារាចរលេខ០៤ស.រ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ របស់រាជរដ្ឋាភិបាល សេចក្តីណែនាំលេខ ០២១ស.ណ.ន ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ និងផែនការសកម្មភាពលេខ ០៥០ ផ.ក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៩ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ស្តីពីការចាត់តាំង អនុវត្តវិធានការបង្ការទប់ស្កាត់ និងបង្ក្រាបសកម្មភាពក្មេងទំនើង) ។

៥-ចាត់វិធានការលុបបំបាត់ល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធ និងលាក់អាវុធខុសច្បាប់

ព្រមទាំងបទល្មើសផ្សេងៗទៀតក្នុងភូមិ ឃុំ សង្កាត់ ដោយអនុវត្តទៅតាមច្បាប់ពាក់ព័ន្ធនានាជាធរមាន ។

**ខ_ផែនការសកម្មភាព :**

១-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តឱ្យបាននូវរបបប្រជុំជាប្រចាំដើម្បីត្រួតពិនិត្យសភាពការណ៍ ដាក់ចេញផែនការ និងវិធានការជាក់ស្តែងក្នុងការអនុវត្តគោលនយោបាយភូមិ,ឃុំមានសុវត្ថិភាពក្នុងវង្វង់សមត្ថកិច្ចទទួលខុសត្រូវរបស់ខ្លួន (ឯកសារយោង សេចក្តីណែនាំលេខ០០៩ ស.ណ.រ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ) ។

គណៈបញ្ជាការរដ្ឋបាលឯកភាពគ្រប់ថ្នាក់ ត្រូវមានសេនាធិការរបស់ខ្លួន ដែលមានសមាសភាពមកពីមន្ទីរអង្គភាពពាក់ព័ន្ធនានា ជាពិសេសនគរបាលជាតិ កងរាជអាវុធហត្ថ នាយក ឬនាយករង រដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

២-នគរបាលប៉ុស្តិ៍រដ្ឋបាលមានតួនាទីយ៉ាងសំខាន់ ដែលចាំបាច់ត្រូវយកចិត្តទុកដាក់ក្នុងការកសាង និងពង្រឹង

កងកម្លាំងនេះ ដើម្បីក្លាយទៅជាកម្លាំងស្នូលពិតប្រាកដនៃចលនាការពារ"ភូមិ,ឃុំ មានសុវត្ថិភាព" និងក្លាយជាសេវាសាធារណៈដែលនៅជាប់ជាមួយប្រជាពលរដ្ឋដោយ :

-ត្រូវរៀបចំឱ្យមានក្របខ័ណ្ឌគ្រប់ចំនួនតាមការកំណត់ស្របតាមលក្ខណៈភូមិសាស្ត្រ និងប្រជាសាស្ត្រ

-ត្រូវធ្វើការបណ្តុះបណ្តាលបំពាក់បំប៉នអំពីតួនាទីភារកិច្ច របៀបរបបធ្វើការ និងសិទ្ធិអំណាចព្រមទាំងសមត្ថភាពជំនាញរបស់នគរបាលប៉ុស្តិ៍រដ្ឋបាល (ឯកសារយោង មេរៀនដកស្រង់ពីក្រុមការងារ ការអនុវត្តសាកល្បង ការពង្រឹងប៉ុស្តិ៍នគរបាលរដ្ឋបាលដើម្បីសហគមន៍)

-ត្រូវរៀបចំឱ្យមានទីកន្លែងធ្វើការ មធ្យោបាយឧបករណ៍ សំភារៈសម្រាប់បំរើការងារ និងរៀបចំឱ្យមានប្រអប់សំបុត្រ និង

-ត្រូវមានកម្លាំងប្តូរវេនប្រចាំការជាអចិន្ត្រៃយ៍

នៅស្នាក់ការនគរបាលប៉ុស្តិ៍រដ្ឋបាលដើម្បីទំនាក់ទំនង ជួប និងទទួលព័ត៌មានពីគ្រប់ប្រភព ។ ក្នុងករណី មានសភាពការណ៍បទល្មើស ឬឧប្បទ្ទវហេតុផ្សេងៗ កើតឡើង ចាំបាច់ត្រូវកោះហៅប្រមូលផ្តុំកម្លាំង ដើម្បីប្រតិបត្តិការណ៍ដោះស្រាយ ។

-ត្រូវមានកិច្ចសហការទំនាក់ទំនងជាមួយ កងកម្លាំងមានសមត្ថកិច្ចនានា ដែលបោះទីតាំងនៅ ក្នុង ឃុំ សង្កាត់ របស់ខ្លួន ដើម្បីបង្កើតឱ្យមាន យន្តការសហការផ្តល់ព័ត៌មាន និងកិច្ចសហការគាំទ្រ គ្នាទៅវិញទៅមកក្នុងការបង្ការទប់ស្កាត់ និងបង្ក្រាប បទល្មើសនានា ក្នុងឃុំ សង្កាត់ ភូមិ និង

-ត្រូវមានទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋ ក្នុងឃុំ សង្កាត់ ភូមិ ដោយមិនត្រូវប្រកាន់និន្នាការ នយោបាយ ជំនឿសាសនា ភេទ ឬស្ថានភាពសង្គម នៃប្រជាពលរដ្ឋម្នាក់ៗដើម្បីឱ្យប្រជាពលរដ្ឋគ្រប់ៗ រូបស្រឡាញ់ជឿទុកចិត្ត ជួយឧបត្ថម្ភគាំទ្រសហការ

ចូលរួមឱ្យបានទូលំទូលាយ ប្រកបដោយទឹកចិត្តស្មោះសរជាមួយនគរបាល និងកងកម្លាំងមានសមត្ថកិច្ចនានាក្នុងចលនា ភូមិ, ឃុំ មានសុវត្ថិភាព ។

៣-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវ :

-ដឹកនាំអង្គភាពនគរបាលតាមថ្នាក់របស់ខ្លួន និងតាមតួនាទី នៃនគរបាលថ្នាក់នីមួយៗដើម្បីដឹកនាំ ត្រួតពិនិត្យ វាយតម្លៃប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ, សង្កាត់ ជាប្រចាំ ។ ជាមួយនេះគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជាឱ្យអង្គភាព នគរបាលជាតិ និងកងរាជអាវុធហត្ថគ្រប់ថ្នាក់ ដើម្បីត្រៀមកម្លាំងអន្តរាគមន៍ជួយដល់នគរបាលប៉ុស្តិ៍ រដ្ឋបាលឃុំ, សង្កាត់នៅពេលមានបទល្មើសកើតឡើង ឬនៅពេលមានសំណូមពរចាំបាច់ ។

-មានកម្មវិធីការងារឱ្យបានច្បាស់លាស់ និងទៀងទាត់ចុះតាមមូលដ្ឋាន ដោយត្រូវយកភូមិធ្វើជា

គោលដៅដើម្បីបំផុសចលនាប្រជាពលរដ្ឋចូលរួមការពារសន្តិសុខ សណ្តាប់ធ្នាប់នៅមូលដ្ឋាន ក្នុងន័យទាក់ទាញឱ្យបានការចូលរួមពីប្រជាពលរដ្ឋ ដើម្បីបង្កើតបានជាកម្លាំងចលករមួយក្នុងការប្រយុទ្ធប្រឆាំងបទល្មើសរក្សាសុវត្ថិភាពភូមិ,ឃុំ ។

៤-ក្រោមការសម្របសម្រួលរបស់រដ្ឋបាលឃុំ,សង្កាត់ ដោយមានការចូលរួមពីប្រជាពលរដ្ឋនៅនឹងកន្លែង និងអ្នកពាក់ព័ន្ធផ្សេងទៀត នៅតាមភូមិនីមួយៗ ឬក្រុមភូមិត្រូវរៀបចំឱ្យមានវេទិការសាធារណៈ ស្តីពីសុវត្ថិភាពភូមិ,ឃុំ។ វេទិការនេះធ្វើឡើងយ៉ាងតិច ១ដង ក្នុង១ត្រីមាស( ឯកសារយោង ផែនការណែនាំបន្ថែមអំពីការចាត់តាំងចលនាការពារសន្តិសុខមាតុភូមិ "ចលនាប្រជាការពារលេខ ០៣៨ផក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៥ របស់ក្រសួងមហាផ្ទៃ) ។ ក្នុងវេទិកានេះត្រូវធ្វើការដោះស្រាយសំណើ សំណូមពរនានារបស់ប្រជាពលរដ្ឋដែលលើកឡើង ។ ក្នុងករណីដោះស្រាយមិនបាន ត្រូវរាយការណ៍ជូនគណៈបញ្ជាការរដ្ឋបាលឯកភាព

ថ្នាក់លើដោះស្រាយ និងត្រូវផ្តល់ព័តិមានត្រឡប់ឱ្យបាន សមស្របជូនប្រជាពលរដ្ឋវិញ ។

៥-ក្រសួងមហាផ្ទៃសូមអំពាវនាវ :

-ដល់គ្រប់ក្រសួង ស្ថាប័នរដ្ឋគ្រប់ថ្នាក់ ដោយផ្អែកទៅតាមតួនាទី ភារកិច្ចរបស់ខ្លួនចេញនូវការណែនាំដល់មន្ត្រី អង្គភាព ក្រោមឱវាទរបស់ខ្លួន ដើម្បីសហការលើកទឹកចិត្ត ឧបត្ថម្ភ គាំទ្រ ចូលរួមជាមួយ ក្រសួងមហាផ្ទៃ គណៈបញ្ជាការរដ្ឋបាលឯកភាពគ្រប់ថ្នាក់ និងសមត្ថកិច្ចអនុវត្តច្បាប់ក្នុងការអនុវត្តគោលនយោបាយភូមិ. ឃុំមានសុវត្ថិភាព ។

-ដល់គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ផ្អែកឯកជន...ផ្អែកតាមតួនាទីភារកិច្ច និងលទ្ធភាពរបស់ខ្លួន ដើម្បីចូលរួមឧបត្ថម្ភគាំទ្រ លើកទឹកចិត្តតាមគ្រប់រូបភាពចូលរួមក្នុងការអនុវត្តគោលនយោបាយភូមិ.ឃុំមានសុវត្ថិភាព ។

៦-ត្រូវចាត់តាំងឱ្យមានចលនាប្រឡងប្រណាំង បង្កើតស្នាដៃ អបអរសាទរសម្រាប់ខួបអនុស្សាវរីយ៍ថ្ងៃបង្កើតកងកម្លាំងនគរបាលជាតិកម្ពុជា ប្រចាំឆ្នាំនីមួយៗ សំដៅស្វែងរកអង្គភាព និងបុគ្គលដែលខិតខំព្យាយាមពុះពារបំពេញភារកិច្ច ហើយបង្កើតបានជាស្នាដៃធំធេងធ្វើជាគំរូក្នុងការអនុវត្តគោលនយោបាយ "ភូមិ,ឃុំ មានសុវត្ថិភាព" (ឯកសារយោង សារាចរណែនាំលេខ ០០១ ស.រ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០០៨ របស់ក្រសួងមហាផ្ទៃ ស្តីពីការបំផុសចលនាប្រឡងប្រណាំងការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម បង្កើតស្នាដៃអបអរសាទរមិទ្ទិញខួបអនុស្សាវរីយ៍ថ្ងៃកំណើតនគរបាលជាតិកម្ពុជា ១៦ ឧសភា ១៩៤៥)។

**IV-ការចាត់តាំងអនុវត្ត :**

១-ក្រសួងមហាផ្ទៃរៀបចំលេខាធិការដ្ឋាន និងក្រុមការងារថ្នាក់ជាតិ ដើម្បីសហការជាមួយគណៈបញ្ជាការ

រដ្ឋបាលឯកភាពគ្រប់ថ្នាក់ដឹកនាំ និងចាត់តាំងអនុវត្តគោល នយោបាយ ភូមិ,ឃុំ មានសុវត្ថិភាពនេះ ។ (ភ្ជាប់ជាមួយ ឧបសម្ព័ន្ធ) ។

២-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រៅពីសេនាធិការរបស់ខ្លួន ត្រូវរៀបចំ ឱ្យមានក្រុមការងារចុះតាមមូលដ្ឋាន ឃុំ, សង្កាត់ ដោយ យកភូមិជាគោលដៅ ដើម្បីសហការអនុវត្តគោលនយោបាយ ភូមិ,ឃុំមានសុវត្ថិភាព ។

៣-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ត្រូវចាត់តាំងបូកសរុបលទ្ធផលអនុវត្តគោលនយោបាយ "ភូមិ, ឃុំ មានសុវត្ថិភាព" ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ផ្ញើមកលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ តាមតារាងទិន្នន័យ ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃផែនការណែនាំនេះដើម្បីមានមូល ដ្ឋានវាយតម្លៃលទ្ធផលនិងស្នាដៃតាមឃុំ,សង្កាត់នីមួយៗ ។

៤-គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ ត្រូវ ចាត់តាំងប្រជុំបូកសរុប ដកពិសោធន៍ និងលើកទិសដៅបន្ត

ក្នុងរយៈពេល ០១ត្រីមាសម្តង ។ សមាសភាពចូលរួមក្នុងអង្គប្រជុំនេះ គឺអ្នកពាក់ព័ន្ធនានានៅក្នុងដែនសមត្ថកិច្ចនៃរដ្ឋបាលរបស់ខ្លួន និងអាស្រ័យដោយប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលសំរេច ។

៥-ដើម្បីទទួលបានបទពិសោធន៏ឈានទៅកែលំអរផែនការចាត់តាំងអនុវត្តគោលនយោបាយ ភូមិ, ឃុំ មានសុវត្ថិភាពនេះឱ្យកាន់តែល្អប្រសើរថែមទៀត គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ អាចជ្រើសរើសមូលដ្ឋានមួយឬពីរ ដើម្បីអនុវត្តសាកល្បង បន្ទាប់មកទើបធ្វើការផ្សព្វផ្សាយ និងចាត់តាំងអនុវត្តជាទូទៅ ។

៦-គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្តក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវមានក្រុមប្រឹក្សាប្រឡងប្រណាំង ដើម្បីបំផុសចលនាប្រឡងប្រណាំងនិងពិនិត្យបូកសរុប វាយតម្លៃលក្ខណៈសម្បត្តិរបស់ភូមិ,ឃុំមានសុវត្ថិភាព ។ តាមរយៈនេះត្រូវរកឱ្យឃើញអង្គភាពនិងបុគ្គលដែលមានស្នាដៃល្អដើម្បីផ្តល់រង្វាន់លើកទឹកចិត្ត ។

៧-អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ត្រូវធ្វើគំរោងថវិកា មធ្យោបាយ សម្ភារៈ បំរើដល់ការចាត់តាំងអនុវត្តគោលនយោបាយ ភូមិ,ឃុំមានសុវត្ថិភាពនេះ ។

ទទួលបានផែនការណែនាំស្តីពីការអនុវត្តគោលនយោបាយ ភូមិ,ឃុំមានសុវត្ថិភាពនេះ ក្រសួងមហាផ្ទៃ សង្ឃឹមថា គ្រប់ក្រសួង ស្ថាប័ន គណៈបញ្ជាការឯកភាពរដ្ឋបាល គ្រប់ថ្នាក់គណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល ផ្នែកឯកជន និងប្រជាពលរដ្ឋគ្រប់រូប នឹងចូលរួមអនុវត្ត និងឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងតាមលទ្ធភាពដែលអាចធ្វើបាន ដើម្បីទទួលបានជោគជ័យក្នុងការកសាងសេចក្តីសុខសុវត្ថិភាពជូនប្រជាពលរដ្ឋយើង ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែ[illegible] ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ៤៤៣ ប្រក

# ប្រកាស
# ស្តីពី
# តួនាទី ភារកិច្ច
# ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់

# ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ ន/ស ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្ត

ទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែល ប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ

-បានឃើញប្រកាសលេខ ០៨១ ប្រ.ក ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៩៤ របស់ក្រសួងមហាផ្ទៃ ស្ដីពីភារកិច្ច សិទ្ធិ និងរចនាសម្ព័ន្ធរបស់ស្នងការដ្ឋាននគរបាលខេត្ត ក្រុង

-បានឃើញប្រកាសលេខ ០៤៣ ប្រ.ក ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៩៨ របស់ក្រសួងមហាផ្ទៃ ស្ដីពីភារកិច្ច សិទ្ធិ និងរចនាសម្ព័ន្ធរបស់អធិការដ្ឋាននគរបាលស្រុក ខណ្ឌ

-បានពិនិត្យសំណូមពរចាំបាច់នៃការងារ

## ស ម្រេ ច

**ប្រការ ១ :** ប៉ុស្តិ៍នគរបាលរដ្ឋបាលស្ថិតនៅក្រោមឱវាទផ្ទាល់របស់មេឃុំ ចៅសង្កាត់ និងស្ថិតនៅក្រោមការដឹកនាំជំនាញផ្ទាល់ពីអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ មានតួនាទីការពារសន្តិសុខសណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមក្នុងឃុំ សង្កាត់ ។

**ប្រការ ២ :** ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់មានភារកិច្ច :

១. គ្រប់គ្រងការចុះស្ថិតិប្រជាពលរដ្ឋ ចំនួនគ្រួសារ ចំនួនមនុស្សស្នាក់នៅបណ្ដោះអាសន្នស្នាក់នៅអចិន្ត្រៃយ៍ និងមុខរបរ ។

២. ចាត់វិធានការគ្រប់គ្រងហ្មត់ចត់មុខសញ្ញាល្មើសច្បាប់នានាក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួន ។

៣. គ្រប់គ្រងការចុះបញ្ជីស្ថិតិអាវុធជាតិផ្ទុះជាតិឆេះ ជាតិពុល កាត់បន្ថយអគ្រោះគ្រោះថ្នាក់ដោយសារអាវុធយុទ្ធភណ្ឌមិនទាន់ផ្ទុះ មុខរបរដែលងាយប៉ះពាល់ដល់សន្តិសុខសណ្ដាប់ធ្នាប់សាធារណៈ និងយានជំនិះគ្រប់ប្រភេទតាមការកំណត់របស់ក្រសួង ។

៤. ចុះបញ្ជីទីតាំងអង្គភាពកងកម្លាំងប្រដាប់អាវុធ ទីតាំងស្ថានទូត គ្រឹះស្ថានសិក្សា វត្តអារាម រមណីយដ្ឋាន ក្លឹបកំសាន្ត អង្គការជាតិ អន្តរជាតិនានា លំនៅដ្ឋានជនបរទេស

ក្រុមហ៊ុន រោងចក្រ សហគ្រាស ។

៥. ចាត់វិធានការបង្ការទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសគ្រប់ប្រភេទដែលកើតឡើងក្នុងមូលដ្ឋានឃុំ សង្កាត់របស់ខ្លួនតាមនីតិ-វិធីច្បាប់ ស្រាវជ្រាវរកមនុស្សបាត់ខ្លួន និងការប្រកាសជាសាធារណៈ ។

៦. សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ការពារកន្លែងកើតហេតុ ប្រមែប្រមូល ថែរក្សាវត្ថុតាង ធ្វើសេចក្ដីរាយការណ៍បឋមជាបន្ទាន់ទៅអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ និងរាយការណ៍ផ្ទាល់ជូនមេឃុំ ចៅសង្កាត់ ។

៧. ទំនាក់ទំនងសហការជិតស្និទ្ធជាមួយសមត្ថកិច្ចនានា ដែលបោះទីតាំងក្នុងភូមិសាស្ត្រឃុំ សង្កាត់របស់ខ្លួន ដើម្បីបង្កើតឱ្យមានយន្តការ សហការផ្ដល់ពត៌មាន និងកិច្ចសហការគាំទ្រគ្នាទៅវិញទៅមក ក្នុងការ

បង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើស ។

៨. អនុវត្តដីកា សាលក្រម និងសាលដីការបស់តុលាការ ។

៩. ល្បាតពួនស្ទាក់ ត្រួតពិនិត្យ តាមចំណុចគោលដៅសំខាន់ៗក្នុងភូមិសាស្ត្រ ឃុំ សង្កាត់របស់ខ្លួន និងអនុវត្តភារកិច្ចសហគមន៍ សំដៅកៀរគរកម្លាំងចូលរួមដើម្បីការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ។

១០. ប្រតិបត្តិម៉ឺងម៉ាត់ និងខ្ជាប់ខ្ជួននូវវិន័យរបស់កងកម្លាំងនគរបាលជាតិ សំដៅធ្វើឱ្យប្រជាពលរដ្ឋស្រឡាញ់រាប់អាន មានទំនុកចិត្ត និងរាយការណ៍រាល់ហេតុការណ៍ដែលកើតឡើង ។

១១. ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងាររបស់ប៉ុស្តិ៍ជូនមេឃុំ ចៅសង្កាត់ និងអធិការដ្ឋាននគរបាល ក្រុង ស្រុក ខណ្ឌតាមការកំណត់ ។

១២. បំពេញភារកិច្ចផ្សេងៗទៀត ដែលអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌប្រគល់ឱ្យ ។

**ប្រការ៣ :** ប៉ុស្តិ៍នគរបាលរដ្ឋបាល ឃុំ សង្កាត់ ត្រូវបានបែងចែកប្រភេទចំនួន ៥ និងកំណត់ចំនួនក្របខ័ណ្ឌដូចខាងក្រោម :

ក-ប៉ុស្តិ៍នគរបាលរដ្ឋបាលប្រភេទ១ មានក្របខ័ណ្ឌចំនួន(២៥-៣០)

ខ-ប៉ុស្តិ៍នគរបាលរដ្ឋបាលប្រភេទ ២ មានក្របខ័ណ្ឌចំនួន (២០-២៥)

គ-ប៉ុស្តិ៍នគរបាលរដ្ឋបាលប្រភេទ ៣ មានក្របខ័ណ្ឌចំនួន (១៥-២០)

ឃ-ប៉ុស្តិ៍នគរបាលរដ្ឋបាលប្រភេទ៤ មានក្របខ័ណ្ឌចំនួន (១០-១៥)

ង-ប៉ុស្តិ៍នគរបាលរដ្ឋបាលប្រភេទ ៥ មានក្របខ័ណ្ឌចំនួន (៧-១០)

**ប្រការ៤ :** ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ដឹកនាំដោយ

នាយប៉ុស្តិ៍១រូប និងមាននាយរងប៉ុស្តិ៍ជាជំនួយការ ។

**ប្រការ៥ :** អំពីភារកិច្ចរបស់នាយប៉ុស្តិ៍នគរបាលរដ្ឋបាល ឃុំ សង្កាត់

១-គ្រប់គ្រងបញ្ជាដឹកនាំត្រួតពិនិត្យកម្លាំង មធ្យោបាយ និងគ្រាប់រំសេវរបស់ប៉ុស្តិ៍នគរបាលរដ្ឋបាល ឃុំ សង្កាត់ ។

២-ដោះស្រាយការងារប្រចាំថ្ងៃរៀបចំរបៀបរបបកម្មវិធី ទិសដៅការងាររបស់ប៉ុស្តិ៍នគរបាលរដ្ឋបាល ព្រមទាំងចាត់តាំងការប្រជុំណែនាំផ្សព្វផ្សាយ និងដាក់ផែនការដល់មន្ត្រីក្រោមឱវាទ ។

៣-ផ្តល់សេវា និងទទួលសំណូមពរពីប្រជាពលរដ្ឋ សហគមន៍ សហគ្រាស រោងចក្រ គ្រឹះស្ថានសិក្សា វត្តអារាម ដើម្បីចាត់វិធានការដោះស្រាយក្នុងសមត្ថកិច្ចរបស់ខ្លួន ។

៤-រៀបចំវេនប្រចាំការអចិន្ត្រៃយ៍ ២៤ ម៉ោង លើ ២៤ម៉ោងដើម្បីទំនាក់ទំនងជួប និង ទទួលពតិមាន ។

៥-បូកសរុបវាយតម្លៃដាក់ពិន្ទុមូលវិចារណ៏ លើកសំណើតែងតាំងឋានៈ ឋានន្តរសក្តិ សរសើរជូនរង្វាន់ដល់មន្ត្រីនគរបាលក្រោម ឱវាទ ដែលមានស្នាដៃក្នុងការបំពេញភារកិច្ច និងត្រួតពិនិត្យអនុវត្តវិន័យ ចំពោះមន្ត្រី នគរបាលអសកម្ម ។

៦-ចុះបញ្ជីការ និងគ្រប់គ្រងចលនៈ អចលនៈ ទ្រព្យក្នុងអង្គភាពរបស់ខ្លួន ។

៧-បំពេញភារកិច្ចផ្សេងៗទៀត ដែលថ្នាក់លើ ប្រគល់អោយ ។

**ប្រការ៦ :** អំពីទំនាក់ទំនង :

-ទំនាក់ទំនងរវាងនាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងមេឃុំ ចៅសង្កាត់ជាទំនាក់ទំនងដឹកនាំ

ណែនាំត្រួតពិនិត្យ ។

-ទំនាក់ទំនងរវាងនាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអធិការនគរបាលក្រុង ស្រុក ខណ្ឌ ជាទំនាក់ទំនង បញ្ជាដឹកនាំការងារជំនាញ ។

-ទំនាក់ទំនងរវាងប៉ុស្តិ៍នគរបាលរដ្ឋបាល និងអង្គភាពពាក់ព័ន្ធ ជាទំនាក់ទំនងសហការដើម្បីសម្រេចភារកិច្ច ។

-ទំនាក់ទំនងរវាងនាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងប្រជាការពារ ជាទំនាក់ទំនងណែនាំចាត់ចែងសកម្មភាព ។

**ប្រការ៧:** ប្រកាសលេខ ៤១៦ ប្រ.ក ចុះថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ១៩៩៩ របស់ក្រសួងមហាផ្ទៃ ស្តីពីតួនាទី ភារកិច្ច សិទ្ធិ និងរចនាសម្ព័ន្ធរបស់ប៉ុស្តិ៍នគរបាលរដ្ឋបាល និងបទបញ្ញត្តិទាំងឡាយណាមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៨ :** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋាន រដ្ឋបាលមូលដ្ឋាន អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ប្រធាននាយកដ្ឋានកណ្តាល ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និងស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

(ដើម្បីជូនជ្រាប)

- ដូចប្រការ ៨ (ដើម្បីអនុវត្ត)
- កាលប្បវត្តិ - ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ ០១៨ សណន

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១១

# សេចក្ដីណែនាំ
# ស្ដីពី
# ការចាត់តាំងចលនាការពារសន្តិសុខមាតុភូមិ
# (ចលនាប្រជាការពារ)

ក្នុងទិសដៅដើម្បីរួមចំណែកពង្រឹងវិធានការរក្សាការពារសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម នាថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៩៩ ក្រសួងមហាផ្ទៃបានចេញលិខិតលេខ ៣៦៤ ស.ជ.ណ ស្ដីពីគំរោងការចាត់តាំងចលនាការពារសន្តិសុខ ។ នាថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៥ ក្រសួងបានចេញលិខិតលេខ ០៣៨ផ.ក ស្ដីពីផែនការណែនាំបន្ថែម អំពីការចាត់តាំងចលនាការពារសន្តិសុខ

មាតុភូមិ (ចលនាប្រជាការពារ) និងចុងក្រោយនេះ លេខាធិការដ្ឋាន អនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព បានចេញលិខិតជូនដំណឹងលេខ ០៦៥ស.ជ.ណ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ ស្តីពីការរៀបចំចលនាប្រជាការពារ តាមសហគមន៍ភូមិឃុំ ប៉ុន្តែប្រការដែលគួរកត់សំគាល់នោះ គឺ ឆ្លងតាមរយៈការចាត់តាំងការអនុវត្តន៍គោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព នាពេលថ្មីៗនេះ ក្រសួងមហាផ្ទៃ បានពិនិត្យឃើញថា : មានមតិជាច្រើនបានលើកឡើងបង្ហាញពីការយល់ដឹងមិនទាន់ឯកភាពគ្នា ឬយល់ដឹងផ្សេងពីគ្នាអំពីចលនាប្រជាការពារ ដែលជាហេតុធ្វើអោយប្រសិទ្ធិភាពនៃការចាត់តាំងអនុវត្តវិធានការនេះនៅមានកំរិត និងមិនទាន់ឆ្លើយតបបានតាមគោលបំណងសំណូមពរដែលប្រាថ្នាចង់បាននៅឡើយ ។

*អាស្រ័យហេតុនេះ ក្រសួងមហាផ្ទៃសូមធ្វើការណែនាំដើម្បីបញ្ជាក់ជាថ្មីដូចតទៅ :*

## ១.អំពីចលនាប្រជាការពារ

-ចលនាប្រជាការពារគឺជាសកម្មភាពចូលរួមដោយស្ម័គ្រចិត្តក្នុងស្មារតីភ្ញាក់រលឹករបស់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានដើម្បីរួមចំណែកការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមនៅមូលដ្ឋានភូមិ ឃុំ ដែលគាត់រស់នៅក្រោមការដឹកនាំ និងសម្របសម្រួលរបស់អាជ្ញាធរមានសមត្ថកិច្ចនៅមូលដ្ឋាននោះ ។

-កម្លាំងប្រជាការពារ គឺជាប្រជាពលរដ្ឋ មន្ត្រីរាជការ បុគ្គលិកអង្គការ សមាគមនានា គ្រប់ស្រទាប់ដែលស្ម័គ្រចិត្តចូលរួមធ្វើសកម្មភាពក្នុងចលនាប្រជាការពារនៅមូលដ្ឋាន ។

-កម្លាំងប្រជាការពារ មិនមែនជាអង្គការចាត់តាំងផ្លូវការ ដែលមានរចនាសម្ព័ន្ធត្រឹមត្រូវឯកភាព ឬមានឯកសណ្ឋានណាមួយពិតប្រាកដទេ ។ ការចងក្រងកម្លាំងប្រជាការពារ គឺអាស្រ័យទៅតាមស្ថានភាពជាក់ស្តែងនៃចំនួនប្រជាពលរដ្ឋដែលបានចូលរួម និងលក្ខណៈភូមិសាស្ត្រ

របស់ ភូមិ ឃុំ នីមួយៗ ដែលតម្រូវឱ្យមានការយាម ល្បាត ដើម្បីការពារអាយុជីវិត ទ្រព្យសម្បត្តិ និងការ បង្ការទប់ស្កាត់បទល្មើស ក៏ដូចជាការរៀបចំសណ្តាប់ធ្នាប់ នៅមូលដ្ឋាន ។

## ២.ភារកិច្ច និងសិទ្ធិ របស់កម្លាំងប្រជាការពារ ៖

-ប្រជាការពារមានភារកិច្ចចូលរួមជាមួយកងកម្លាំង នគរបាល ឬកងរាជអាវុធហត្ថ ឬ អាជ្ញាធររដ្ឋបាលដែនដី ក្នុងការយាមល្បាតការពារសន្តិសុខ ភូមិ ឃុំ ការពារកន្លែង កំសាន្ត សប្បាយ ពិធីបុណ្យទាន ឬការរៀបចំសណ្តាប់ធ្នាប់ នៅទីសាធារណៈណាមួយតាមការចាត់តាំងរបស់អាជ្ញាធរ មានសមត្ថកិច្ចនៅមូលដ្ឋាននោះ ។

-ប្រជាការពារមានភារកិច្ចជួយក្រើនរំឭកដាស់តឿន ប្រជាពលរដ្ឋក្នុងមូលដ្ឋានអោយចេះប្រុងប្រយ័ត្ន ការពារ ទ្រព្យសម្បត្តិ ផ្ទះសំបែង សត្វពាហនៈ...រំលឹកដាស់តឿនរាល់ ការ ឆ្វេសប្រហែសនានា ដែលជាអំណោយផល ងាយស្រួល

ដល់ការប្រព្រឹត្តិបទល្មើស និងជួយអប់រំយុវជន យុវនារី ក្នុងមូលដ្ឋានអោយអនុវត្តល្អ ជៀសវាងនូវរាល់អំពើអបាយមុខផ្សេងៗ ព្រមជាមួយនោះក៏មានភារកិច្ចរាយការណ៍អំពីមុខសញ្ញា ឬបាតុភាពសង្ស័យទាក់ទិនដល់សន្តិសុខ សណ្តាប់ធ្នាប់ ជូននគរបាល ដើម្បីចាត់វិធានការការពារសុវត្ថិភាពភូមិ ឃុំមានប្រសិទ្ធិភាព ។

-ប្រជាការពារមានសិទ្ធិឃាត់ចាប់ជនប្រព្រឹត្តបទល្មើសជាក់ស្តែងនានាដើម្បីប្រគល់អោយនគរបាល ឬ កងរាជអាវុធហត្ថ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។

-ប្រជាការពារពុំមានសិទ្ធិទទួលបាននូវការបំពាក់អាវុធដើម្បីធ្វើសកម្មភាពទេ ។

## ៣.ការកសាងកម្លាំងប្រជាការពារ :

ការកសាងកម្លាំងប្រជាការពារ ត្រូវធ្វើឡើងតាមលក្ខការណ៍ស្ម័គ្រចិត្ត ដោយមិនបង្ខំ ឬមធ្យោបាយណាមួយ

ផ្ទុយពីនេះឡើយ ។

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេភូមិ ដោយមាននគរបាលប៉ុស្តិ៍រដ្ឋបាលជាជំនួយការ ត្រូវរៀបចំការបំផុសចលនាប្រជាជននៅក្នុងមូលដ្ឋានរបស់ខ្លួន សំដៅធ្វើអោយមានការយល់ដឹង ដោយភ្ញាក់រលឹកថា ការចូលរួមក្នុងចលនាប្រជាការពារ ឬការជួយឧបត្ថម្ភដល់ចលនាប្រជាការពារ គឺជាការការពារអាយុជីវិត ទ្រព្យសម្បត្តិរបស់ក្រុមគ្រួសារខ្លួន និងខ្លួនឯង ដែលផ្តើមពីនោះនឹងធ្វើអោយចលនានេះមានធាតុសកម្ម ផុលផុស នឹងមានការចូលរួមសស្រាក់សស្រាំ ។

-ប្រជាពលរដ្ឋទាំងពីរភេទ គ្រប់វណ្ណៈ ដោយមិនមានការរើសអើង គិតទាំងនិន្នាការនយោបាយ និងសាសនាផង ត្រូវបានទទួលអនុញ្ញាតអោយចូលរួមជាកម្លាំងប្រជាការពារ ក្នុងបំណងប្រមែប្រមូលកម្លាំងសរុប វិធានការសរុប អោយបានច្រើនកុះករក្នុងបុព្វហេតុការពារសន្តិសុខមាតុភូមិ ។

-ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេភូមិ ដោយមាននគរបាលប៉ុស្តិ៍រដ្ឋបាលជាជំនួយការ ត្រូវមានកម្មវិធីប្រជុំជាមួយកម្លាំងប្រជាការពារ ដើម្បីធ្វើការផ្សព្វផ្សាយ ជូនដំណឹងអំពីសភាពការណ៍ចាំបាច់នានា គោលការណ៍របស់ឃុំ សង្កាត់ ច្បាប់ទម្លាប់ផ្សេងៗ សភាពការណ៍សន្តិសុខនៅក្នុងភូមិសាស្ត្រ ការប្រឹក្សាយោបល់អំពីវិធានការ ក៏ដូចជាការថែបំប៉នចិត្តសាស្ត្រ ព្រមទាំងត្រូវមានការស្នើឡើងដើម្បីសរសើរជូនរង្វាន់ដល់បុគ្គលដែលមានស្នាដៃឆ្នើមក្នុងការចូលរួមចលនាការពារសន្តិសុខ សណ្តាប់ធ្នាប់ភូមិ ឃុំ ផងដែរ ។

## ៤.របៀបធ្វើសកម្មភាពរបស់ប្រជាការពារ

ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេភូមិ ដោយមាននគរបាលប៉ុស្តិ៍រដ្ឋបាលជាជំនួយការ ត្រូវផ្អែកលើភូមិសាស្ត្រជាក់ស្តែង និងសភាពការណ៍សន្តិសុខ សណ្តាប់ធ្នាប់របស់មូលដ្ឋានខ្លួនដើម្បីរៀបចំទីតាំងយាមកាម ឬគំរោង

ការដើរល្បាតសំដៅបង្ការទប់ស្កាត់បទល្មើស ក៏ដូចជារៀបចំសណ្តាប់ធ្នាប់សាធារណៈនៅតាមទីកន្លែងមួយចំនួនដែលចាំបាច់ ។

-រៀបចំចងក្រងកម្លាំងប្រជាការពារជាក្រុម និងរៀបចំបញ្ជី តារាងវេនយាមល្បាតតាមចំនួនជាក់ស្តែង និងចាត់តាំងការយាមល្បាតការពារភូមិ ឃុំដោយមាននគរបាលម្នាក់ចូលរួមជាស្នូលបង្អែកសំរាប់ជួយគាំទ្រខាងផ្នែកអាវុធច្បាប់ ក៏ដូចជាស្មារតី ។

ក្នុងករណីពុំមានកម្លាំងនគរបាលចូលរួមជាមួយក្រុមយាមល្បាត ត្រូវរៀបចំឱ្យមានតំណាងអាជ្ញាធរមូលដ្ឋាន និងរៀបចំអោយមានមធ្យោបាយសំរាប់ទាក់ទងជាមួយនគរបាល ដើម្បីជួយធ្វើអន្តរាគមន៍ពេលមានសភាពការណ៍កើតឡើង ។

គោលដៅសកម្មភាពរបស់កម្លាំងប្រជាការពារសំខាន់គឺការជួយបង្ការ ទប់ស្កាត់សកម្មភាពបទល្មើសព្រហ្មទណ្ឌគ្រឿងញៀន ការជួញដូរមនុស្ស សកម្មភាពក្មេងទំនើង

ការលេងល្បែងស៊ីសងខុសច្បាប់  និងជួយរក្សាសណ្តាប់ធ្នាប់សាធារណៈនៅមូលដ្ឋាន ។

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ខេង

ចម្លងជូន :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន រដ្ឋលេខាធិការដ្ឋាន
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- អគ្គនាយកដ្ឋានរដ្ឋបាល មូលដ្ឋាន
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ

បោះពុម្ពដោយ

អគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ